**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៤.០៦៥/០៨ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

# គ.ជ.ប ផ្សព្វផ្សាយពីដំណើរការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ វេលាម៉ោង១០ព្រឹក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បាន រៀបចំសន្និសីទសារព័ត៌មាន ស្តីពីដំណើរការនៃការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

ឯកឧត្តម សោម ច័ន្ទឌីណា សមាជិក គ.ជ.ប និងជាប្រធានដឹកនាំសន្និសីទបានមានប្រសាសន៍ថា ដំណើរការនៃការ ចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ចាប់ផ្តើមពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០០៨ ហើយតម្រូវឱ្យគណបក្សនយោបាយទាំងអស់បំពេញតាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ បទបញ្ជា និងនីតិវិធី ។

ឯកឧត្តមបានបញ្ជាក់ថា ក្នុងរយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃ៣០ ខែមេសា ឆ្នាំ២០០៨ នេះ គ.ជ.ប បាន ទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយបានចំនួន ៣គណបក្ស រួមមាន : គណបក្សប្រជាជនកម្ពុជា, គណបក្សសង្គមខ្មែរ និយម និងគណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ ។

ឯកឧត្តមបានរំលឹកថា កាលពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៣ នៅឆ្នាំ២០០៣ មានគណបក្សនយោបាយ ចំនួន២៣ បានចូលរួមប្រកួតប្រជែង ហើយសម្រាប់ឆ្នាំនេះមិនទាន់កំណត់បានថា មានគណបក្សនយោបាយចំនួនប៉ុន្មាននឹង ចូលរួម ។ ប៉ុន្តែឯកឧត្តមបានឱ្យដឹងថា មានគណបក្សនយោបាយប្រមាណ ៤៥ គណបក្ស បានចុះបញ្ជីគណបក្សនយោបាយនៅ ក្រសួងមហាផ្ទៃ ។ ឯកឧត្តមក៏បានអំពាវនាវផងដែរដល់គណបក្សនយោបាយផ្សេងៗទៀតដែលមានបំណងចូលរួមប្រកួតប្រជែង ក្នុងការបោះឆ្នោតនេះឱ្យរៀបចំដាក់ពាក្យឱ្យបានលឿនមក គ.ជ.ប ដើម្បីឱ្យ គ.ជ.ប ពិនិត្យ និងសម្រេច ។

នៅក្នុងសន្និសីទនេះដែរ តំណាងគណបក្សនយោបាយបានលើកឡើងពីការលំបាកក្នុងការបញ្ជាក់ឯកសារពីឃុំ សង្កាត់ ដោយ ឃុំ សង្កាត់សំអាងលើហេតុផលផ្សេងៗដូចជា សុំឱ្យបិទរូបថត ឯកសារមិនគ្រប់គ្រាន់ជាដើម ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា បើគណបក្សនយោបាយជួបការលំបាកក្នុងការ បញ្ជាក់ឯកសារផ្សេងៗទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតនៅខេត្ត ក្រុងណាមួយអាច ជូនដំណឹងជាបន្ទាន់ទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ដើម្បីឱ្យពួកគាត់ជួយសម្រួល និងដោះស្រាយបញ្ហាទាំង នោះ ។ ទាក់ទងនឹងការងារនេះដែរ ឯកឧត្តមបានបញ្ជាក់ថា គ.ជ.ប បានណែនាំទៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈលេខា ធិការដ្ឋានខេត្ត ក្រុងរួចហើយក្នុងការបញ្ជាក់លិខិត ឬឯកសារឱ្យបេក្ខជន ឬតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។